# ទិដ្ឋភាពរបស់អង្គការ សេដាក កសិកម្ម និងការអភិវឌ្ឍជនបទ

## ខែមករា ឆ្នាំ ២០០៩

## អំពីវិស័យកសិកម្មប្រទេសកម្ពុជា

- សង្គមកសិកម្ម: ប្រជាជន ៧៥% ពឹងអាស្រ័យលើវិស័យកសិកម្ម
- ចំនួនប្រជាជនសរុប: ១៤ លាននាក់
- ផ្ទៃដីដែលអាចដាំដុះបាន: មានទំហំ ៦ ទៅ ៦.៥ លានហិកតា។ ហើយផ្ទៃដីដែលបានធ្វើការដាំដុះជាក់ស្តែង: មានទំហំ ៣ ទៅ ៣.៥ លានហិកតា។
- ចំនួនផ្ទៃដីកម្មសិទ្ធិជាមធ្យម: ១.២ ហិកតាក្នុងមួយគ្រួសារ (សមាជិក ៥ នាក់)
- គ្រួសារប្រជាជនចំនួនច្រើនជាង ៨0% មានដីតិចជាង ២ ហិកតា
- កសិករក្រីក្រ ជាពិសេសកសិករធ្វើស្រែ គឺមានចំនួនច្រើនលើសលុប

## អំពីអង្គការ សេដាក

- សេដាក បានបង្កើតឡើងនៅខែសីហា ឆ្នាំ ១៩៩៧ ដោយជនជាតិខ្មែរចំនួន ៧ នាក់និងដោយមានការផ្តួចផ្តើមគំនិតដំបូងពី អង្គការបារាំង ហ្គ្រេត (GRET)
- បេសកកម្មរបស់យើងគឺដើម្បីកសាង *"សង្គមកម្ពុជាមួយ ដែលគ្រួសារកសិករមានជីវភាពធូរធារ មានការសហការគ្នាទៅវិញទៅមក មានសិទ្ធិ និងអំណាចគ្រប់គ្រាន់ក្នុងការ សម្រេចចិត្តទៅលើជោគវាសនា របស់ខ្លួន ហើយនិងមានតួនាទីយ៉ាងសំខាន់ ក្នុងការផ្គត់ផ្គង់នូវស្បៀងអាហារប្រកប ដោយសុខភាព ដល់សង្គមកម្ពុជាទាំងមូល"*។

## ទិដ្ឋភាពនៃកម្មវិធីស្នូលរបស់អង្គការ សេដាក

- **កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន សេដាក:** ការពង្រឹងសមត្ថភាព គាំទ្រការគ្រប់គ្រង និង ភាពជាអ្នកដឹកនាំ ទៅដល់គ្រួសារកសិករក្រីក្រ
- **កម្មវិធីសហគ្រាស សេដាក ដើម្បីអភិវឌ្ឍន៍សង្គម:** ការអភិវឌ្ឍន៍ទីផ្សារសម្រាប់ផលិតផលរបស់កសិករ ជាពិសេសផលិតផលសរីរាង្គ (តាមគោលការណ៍ធម្មជាតិ) និងផ្តល់ការគាំទ្រទាក់ទងទៅនឹងពាណិជ្ជកម្ម និងទីផ្សារទៅដល់សហគមន៍

- **វិទ្យាស្ថានសេដាក ដើម្បីអភិវឌ្ឍន៍មូលដ្ឋាន:** ពង្រឹងសមត្ថភាពយុវជនជនបទ ដើម្បីធ្វើការបំរើដល់ អង្គការកសិករ និងជំនួញសហគមន៍

## កម្មវិធីផ្សេងទៀតរបស់អង្គការ សេដាក

### សេវាកម្មប្រឹក្សាយោបល់ស្រាវជ្រាវ និងការអភិវឌ្ឍន៍

- ការសិក្សាអំពីមូលដ្ឋានគ្រឹះ និងលទ្ធភាពរបស់គម្រោង
- ការតាមដាន និងវាយតម្លៃគម្រោង
- សេវាកម្មប្រឹក្សាយោបល់ផ្សេងៗទៀត ដែលផ្តោតលើការស្រាវជ្រាវ

### ការបោះពុម្ពផ្សាយ និងទំនាក់ទំនង

- ការបោះពុម្ពនូវឯកសារចំណេះដឹង ព័ត៌មាន និងផ្សព្វផ្សាយនូវបច្ចេកទេសផ្សេងៗទៀត
- កម្មវិធីវិទ្យុ ដើម្បីចែករំលែកចំណេះដឹង បទពិសោធន៍ពីគ្នាទៅវិញទៅមក ជាពិសេស ពីកសិករទៅកសិករ
- ការផលិត និងចែកផ្សាយនូវឯកសារព័ត៌មានអំពី សេដាក

### បរិស្ថាន និងសុខភាព

- ការតាមដានដល់ការប្រើប្រាស់នូវថ្នាំពុល និងថ្នាំគីមីផ្សេងៗទៀត
- ការចងបណ្តាញ និងអប់រំទៅដល់អ្នកប្រើប្រាស់ ( អ្នកបរិភោគ)
- សេវាកម្មលើផ្នែកត្រួតពិនិត្យគុណភាព និងវិញ្ញាប័ណ្ណប័ត្រផលិតផលសរីរាង្គ

## ទិដ្ឋភាពទូទៅអំពីការគ្របដណ្តប់ និងឥទ្ធិពលរបស់កម្មវិធី

- សេដាក កំពុងធ្វើការជាមួយគ្រួសារកសិករចំនួន **៩០ 000 គ្រួសារ** ( ប្រមាណ ៥% នៃគ្រួសារកសិករ ទូទាំងប្រទេស) និងប្រមាណ ៤៥០ 000 នាក់ ដើម្បីពង្រឹងលក្ខ័ណនៃការរស់នៅរបស់ពួកគាត់ និង លក្ខ័ណនៅក្នុងសហគមរបស់ពួកគាត់
- នៅក្នុងភូមិចំនួន **២៨០០ ភូមិ** ( ប្រមាណ ២០% នៃចំនួនភូមិនៅក្នុងប្រទេសកម្ពុជា) និង ៥០០ ឃុំ ( ប្រមាណ ៣០% នៃចំនួនឃុំទូទាំងប្រទេស) និងនៅក្នុង ២០ ខេត្ត នៃ ២៤ ខេត្តក្រុងទូទាំងប្រទេស

- យុវជនជនបទច្រើនជាង **៣០០ នាក់** កំពុងស្ថិតនៅក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញ កសិកម្ម និង អភិវឌ្ឍន៍ជនបទ
- អ្នកពាក់ព័ន្ធប្រមាណជាង ១០០០ នាក់ផ្សេងទៀត ជាពិសេសគឺគ្រូបង្រៀននៅតាមសាលា និង អង្គាធរ មូលដ្ឋានកំពុងតែធ្វើការសហការគ្នាជាមួយ សេដាក ដើម្បីជម្រុញការអភិវឌ្ឍន៍ដោយអាស្រ័យលើខ្លួនឯង
- កសិករ ៧០ ០០០ គ្រួសារកំពុងបង្កើនផលិតកម្មកសិកម្ម ដោយការប្រើប្រាស់នូវគំនិតរកឃើញថ្មីៗ នៅក្នុង  កសិកម្មតាមគោលការណ៍ធម្មជាតិ ជាពិសេសគឺ **ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ ធម្មជាតិ** (ប.វ.ស)
- ប.វ.ស.ត្រូវបានណែនាំដំបូងដោយ អង្គការ សេដាក ហើយបានធ្វើការផ្សព្វផ្សាយទៅដល់ទូទាំងប្រទេស ដោយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀត (កសិករដែលអនុវត្តប.វ.ស. មានច្រើន ជាង ១០០ ០០០ នាក់)
- ក្រុមសន្សំប្រាក់មាន ៤៥០០ ក្រុមជាមួយនិងសមាជិក ៧០ ០០០ នាក់ (ស្ត្រីជាង ៥០%) និង មានទុន សន្សំចំនួន ១.៦ លានដុល្លារអាមេរិក
- ក្រុមផលិតក្រីក្រចំនួន ៨០០០ ក្រុមត្រូវបានផ្សារភ្ជាប់មកកាន់ទីផ្សារ

## ទិដ្ឋភាពទូទៅរបស់កម្មវិធី   អភិវឌ្ឍន៍មូលដ្ឋាន

**កម្មវិធីអភវឌ្ឍន៍មូលដ្ឋានរបស់យើងផ្តោតលើការពង្រឹងសមត្ថភាព ការគាំទ្រ ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំទៅដល់:**

- ការផ្សព្វផ្សាយពីកសិករទៅកសិករ
- ក្រុមសន្សំប្រាក់ និងបណ្តាញ (ការសន្សំប្រាក់ដើម្បីភាពអាស្រ័យលើខ្លួនឯង)
- អង្គការអ្នកផលិត
- អង្គការជំនួញសហករណ៍
- ការអភិវឌ្ឍន៍សហគមន៍ ឬសមាគមន៍អភិវឌ្ឍន៍មូលដ្ឋាន
- សហគមន៍កសិករអ្នកប្រើប្រាស់ទឹក

## ការផ្សព្វផ្សាយពីកសិករទៅកសិករ

- ការកំណត់ និងជ្រើសរើសនូវកសិករដែលមានសក្តានុពល ដើម្បីធ្វើការគាំទ្រឱ្យក្លាយ ជាកសិករបង្គោល និងកសិករផ្សព្វផ្សាយ
- ការបណ្តុះបណ្តាលដល់ កសិករបង្គោល និងកសិករផ្សព្វផ្សាយ
- ការគាំទ្រដល់ការចាប់ផ្តើមនូវ ការបង្ហាញកសិដ្ឋានគំរូ ដើម្បីបង្រៀនដល់កសិករ
- ការគាំទ្រ និងការអភិវឌ្ឍន៍បណ្តាញកសិករបង្គោល និងកសិករផ្សព្វផ្សាយ ដើម្បីផ្តល់ ជូននូវសេវាកម្មបច្ចេកទេស និងវត្ថុធាតុដើមមួយចំនួនដូចជា ( គ្រាប់ពូជ  កូនមាន់ កូនជ្រូក ជាដើម) ទៅដល់កសិករផ្សេងទៀត

## ក្រុមសន្សំប្រាក់   និងបណ្តាញ

- ការកំណត់នូវអ្នកភូមិដែលចំណាប់អារម្មណ៍ធ្វើការជាមួយគ្នា លើការចងក្រងក្រុមសន្សំប្រាក់នៅតាម ភូមិ
- ការបណ្តុះបណ្តាលដល់អ្នកដឹកនាំក្រុម
- ការគាំទ្រដល់ការបង្កើតសមាគមន៏ភូមិនៃក្រុមនសន្សំ
- ការបណ្តុះបណ្តាល់ដល់អ្នកសម្របសម្រួលក្រុមសន្សំប្រាក់
- ការអភិវឌ្ឍន៏បណ្តាញនៃអ្នកសម្របសម្រួលក្រុមសន្សំថ្នាក់ភូមិ
- ការគាំទ្រដល់ការគ្រប់គ្រង និងពង្រឹងសមត្ថភាពទៅដល់អ្នកសម្របសម្រួលបណ្តាញ

## អង្គការអ្នកផលិត

**ក. ជួយដល់ការបង្កើតក្រុមផលិត**

- សហករណ៏អ្នកផលិតស្រូវសរីរាង្គ
- ក្រុមអ្នកផលិតបន្លែសរីរាង្គ
- ក្រុមអ្នកផលិតមាន់
- សហករណ៏ទីផ្សារ និងអ្នកផលិតជ្រូក

**ខ. ការការគាំទ្រដល់ការគ្រប់គ្រង និងពង្រឹងសមត្ថភាព ទៅដល់អ្នកដឹកនាំ និងអ្នកគ្រប់គ្រងក្រុម និងសហករណ៏**

គ. ការផ្សារភ្ជាប់អ្នកផលិតមកាន់ទីផ្សារដែលបានបង្កើត ឬអភិវឌ្ឍន៍ដោយ សេដាក

## អង្គការជំនួញសហករណ៍

- ប្រភេទនៃជំនួញសហករណ៍
  - តួបសហគមន៍
  - សហករណ៍រោងម៉ាស៊ីនកិនស្រូវ
  - សហករណ៍ផលិតចំណីសត្វ
- **ជំនួយរបស់ សេដាក**
  - ការសម្របសម្រួលដំណើរការនៃការបង្កើតសហករណ៍
  - ការពង្រឹងសមត្ថភាពដល់អ្នកដឹកនាំ និងអ្នកគ្រប់គ្រង
  - ការគាំទ្រការចងបណ្តាញរវាងអ្នកដឹកនាំសហករណ៍
  - ការផ្សារភ្ជាប់ទៅកាន់អ្នកវិនិយោគដែលមានសក្តានុពល

## ការអភិវឌ្ឍន៍សហគមន៍ ឬសមាគមន៍អភិវឌ្ឍន៍មូលដ្ឋាន និងបណ្តាញ

**ការកសាងសមត្ថភាព ការបែងចែកធនធាន ការផ្តល់ការគាំទ្រផ្នែកការដឹកនាំ និងគ្រប់គ្រងទៅដល់កំរិតផ្សេងគ្នានៃអង្គការ**

- បណ្តាញអភិវឌ្ឍន៍ថ្នាក់ភូមិ (បណ្តាញនៃតំណាងក្រុមជួយខ្លួនឯងនៅតាមភូមិ)
- បណ្តាញអភិវឌ្ឍន៍ថ្នាក់ឃុំ (បណ្តាញនៃតំណាង បណ្តាញអភិវឌ្ឍន៍ថ្នាក់ភូមិ)
- បណ្តាញស្រុក ឬសមាគមន៍អភិវឌ្ឍន៍ថ្នាក់ស្រុក (បណ្តាញនៃតំណាងបណ្តាញឃុំ)
- បណ្តាញខេត្ត ( បណ្តាញនៃតំណាងបណ្តាញថ្នាក់ស្រុក )
- បណ្តាញថ្នាក់ជាតិ ( បណ្តាញនៃតំណាងបណ្តាញថ្នាក់ខេត្ត )

## ការអភិវឌ្ឍន៍ទីផ្សារផលិតផល

- ប្រតិបត្តិការ **ហាងទីផ្សារកសិផល និងធម្មជាតិ** សេដាក ចំនួន ៣ នៅក្នុងទីក្រុង ភ្នំពេញ
- **ការលក់ដុំ និងចែកចាយ** នូវផលិតផលទីផ្សារកសិផល និងធម្មជាតិ ទៅដល់អ្នកលក់រាយ ផ្សារទំនើប សណ្ឋាគារ និងភោជនីយដ្ឋាននៅទីក្រុងភ្នំពេញ សៀមរាប និង ខេត្តព្រះសីហនុ
- ពាណិជ្ជកម្ម និងទីផ្សារ និងការវិនិយោគគាំទ្រដល់ **ជំនួញសហគមន៍ ឬជំនួញសហករណ៍**

- **កម្មវិធីអប់រំអ្នកបរិភោគ**តាមរយៈកម្មវិធីវិទ្យុ ឯកសារព័ត៌មាន ការប្រជុំជាមួយអ្នក បរិភោគ និង ទស្សនៈកិច្ចសិក្សារបស់ក្រុមអតិថិជនទៅកាន់មូលដ្ឋាន

## ការបណ្តុះបណ្តាលជំនាញដល់យុវជនជនបទ

- ក្រុមគោលដៅ: **យុវជនជនបទដែលបានរៀនត្រឹមកំរិតថ្នាក់វិទ្យាល័យ និងជាកូនចៅកសិករក្រីក្រ**
- វិជ្ជាជីវៈរបស់សិក្ខាកាមៈ អ្នកគ្រប់គ្រងកសិដ្ឋាន អ្នកគ្រប់គ្រងអង្គការកសិករ អ្នកសម្របសម្រួលក្រុមសន្សំប្រាក់ ជំនួញសហគមន៍ និងអ្នកសម្របសម្រួលការអភិវឌ្ឍន៍មូលដ្ឋាន
- ការបង្រៀនសុទ្ធរយៈពេលមួយឆ្នាំ និងការបង្រៀនដោយតាមដានរយៈពេលមួយឆ្នាំ
- ការបណ្តុះបណ្តាលផ្សារភ្ជាប់ទៅនឹង**ការងារមូលដ្ឋាន**ជាក់ស្តែងៈ បណ្តុះបណ្តាលរយៈពេលមួយទៅពីរសប្តាហ៍ និងចុះអនុវត្តផ្ទាល់ និងលំហាត់កិច្ចការផ្ទះ រយៈពេលពីរទៅបី សប្តាហ៍

## *សង្ខេបនូវយុទ្ធសាស្ត្រសំខាន់ៗៈ អ្វីដែលយើងអាចធ្វើបាន យើងនឹងធ្វើឱ្យអស់ពីលទ្ធភាព*

- កសាងសមត្ថភាពកសិករ ដោយប្រើប្រាស់នូវវិធីសាស្ត្រ**ភាពអាស្រ័យលើខ្លួនឯង ការគិតជាវិជ្ជមាន** និងវិធីសាស្ត្រ**មូលដ្ឋានគ្រឹះទីផ្សារ**
- ការរួមបញ្ចូលនូវការគាំទ្រផ្នែក**ផលិតកម្ម ជំនួញឬទីផ្សារ និងកាសន្សំឬឥណទាន** ដើម្បីបង្កើតនូវប្រសិទ្ធិភាព នៅក្នុងតំបន់មួយជាក់លាក់
- ការជ្រើសរើសនូវ**អ្នកដឹកនាំមូលដ្ឋាន ឬអ្នកដឹកនាំក្រុម និងសហគ្រិន**ដែលពោពេញ ដោយសក្តានុពល ដើម្បីកសាងនូវសមត្ថភាពរបស់ពួកគាត់ ធ្វើការអភិវឌ្ឍន៍ ដឹកនាំ និងគ្រប់គ្រងកសិដ្ឋានរៀនសូត្រ អង្គការកសិករ និងជំនួញសហគមន៍

## សង្ខេបនូវយុទ្ធសាស្ត្រសំខាន់ៗ

- ការលើកទឹកចិត្ត និងគាំទ្រ**បណ្តាញរវាងអ្នកដឹកនាំក្រុមឬអ្នកដឹកនាំមូលដ្ឋាន សហគ្រិនជនបទ**ក្នុងគោលបំណងរៀនសូត្រ ចែករំលែក ការពង្រឹងអំណាចគ្នាទៅវិញទៅមក និងសកម្មភាពសហការគ្នា ដើម្បីផលប្រយោជន៍ទាំងអស់គ្នា។

- ការវិនិយោគទៅលើ**យុវជនជនបទ** ឱ្យក្លាយទៅជាអ្នកដឹកនាំជនបទ សហគ្រិន និងអ្នកសម្រុះសម្រួលជនបទ និងអ្នកគ្រប់គ្រងសហករណ៍និងអង្គការអ្នកផលិត
- ជម្រុញ**អភិបាលកិច្ចមូលដ្ឋាន** ធ្វើការពាក់ព័ន្ធនិងកម្មវិធីអភិវឌ្ឍន៍ជនបទ និងការគាំទ្រការអភិវឌ្ឍនូវ**អភិបាលកិច្ចមូលដ្ឋានល្អ**
- កាចែកចាយទុន ពី**អ្នកវិនិយោគដែលមានការទទួលខុសត្រូវចំពោះសង្គម** ដើម្បីគាំទ្រដល់ជំនួញសហករណ៍ឬសហគមន៍

## អ្វីដែលយើងអាចធ្វើបាន   យើងនឹងធ្វើឱ្យអស់ពីលទ្ធភាព

